ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ០០៥/១៤-ឃែនធើរេន អ៊ីកែរីល (ខេមបូឌា)
កាលបរិច្ឆេទនៃសេចក្តីបង្គាប់ ៖ ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៤

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ **ម៉ារ សំបូរណា**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ **អន ណន**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ **គង់ ផល្លះ**

## ភាគីនៃវិវាទ

### ១- ភាគីនិយោជក

ឈ្មោះ ៖ **ក្រុមហ៊ុន ឃែនធើរេន អ៊ីកែរីល (ខេមបូឌា)**

អាសយដ្ឋាន ៖ ភូមិត្រពាំងថ្លឹង សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០១២ ៨៥ ២២ ០០ ទូរសារ ៖ គ្មាន

តំណាងភាគីនិយោជកចូលរួមកិច្ចប្រជុំមុនសវនាការ ៖

- លោក លាវ គីមប៊ូ ប្រធានរដ្ឋបាល

### ២- ភាគីកម្មករនិយោជិត

ឈ្មោះ ៖ **តំណាងកម្មករ**

អាសយដ្ឋាន៖ ភូមិត្រពាំងថ្លឹង សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០១៧ ៥៨៨ ២៤៦ ទូរសារ ៖ គ្មាន

តំណាងភាគីកម្មករនិយោជិតចូលរួមប្រជុំមុនសវនាការ ៖

១- លោក ស៊ុត ចិត្រ មន្ត្រី CUMW

២- លោក ជា ឧត្តម មន្ត្រី CUMW

៣- លោកស្រី យិន សុផា ប្រធានសហជីពចលនាកម្មករ

៤- លោកស្រី អ៊ឹម សុផល អនុប្រធានសហជីពចលនាកម្មករ

៥- លោកស្រី អ៊ឹម ភក្តី កម្មករ

៦- លោក ស៊ាង យ៉ូត មន្ត្រីសហជីព CCAWDU

៧- លោក សុត សៀម មន្ត្រីសហជីព CCAWDU

៨- លោកស្រី ឃួន សុខា ប្រធានសហជីព

៩- លោក ឆេង គឹមស្រន់ លេខាសហជីព

១០- លោក ឃុត សារឿន សកម្មជន

១១- លោក ចាប ដា សកម្មជន

១២- កញ្ញា សុខ ម៉ាលី តំណាងកម្មករ

១៣- កញ្ញា ណុប សុផាន តំណាងកម្មករ

១៤- កញ្ញា ហោ ស៊ីម សកម្មជន

១៥- កញ្ញា ផុន ទូច កម្មការិនី

១៦- លោក ជា សារិត សកម្មជន

១៧- លោក អ៊ុំ វាសនា សកម្មជន

១៨- កញ្ញា លី ធារី សកម្មជន

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

កម្មនិយោជិតនៅតែទាមទារសុំឱ្យក្រុមហ៊ុនផ្តល់ប្រាក់ឈ្នួល ១០០ % ក្នុងអំឡុងពេលធ្វើកូដកម្ម ចាប់ពីថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៣ និងថ្ងៃទី០២ ខែមករា ឆ្នាំ២០១៤។ ដោយឡែកភាគីនិយោជកបញ្ជាក់ថា ក្រុមហ៊ុនមិនអាចផ្តល់ប្រាក់ឈ្នួលក្នុងអំឡុងពេលកូដកម្មនោះទេ ប៉ុន្តែ ប្រាក់រង្វាន់ធ្វើការងារទៀងទាត់ និងអត្ថប្រយោជន៍ផ្សេងៗ ក្រុមហ៊ុនរក្សាឱ្យនៅដដែល។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សា

អាជ្ញាកណ្តាលលេខ ១៥៥ កប/ប្រក ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៣ (អាណត្តិទី១១)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការដោះស្រាយវិវាទការងាររួម លេខ ០២១ កប/អក/វក ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១៤ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី១០ ខែមករា ឆ្នាំ២០១៤។

**សវនាការ និង សង្ខេបនីតិវិធី**

**ទីកន្លែងសវនាការ ៖** ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទកិច្ចប្រជុំមុនសវនាការ ៖** ថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១៤ (វេលាម៉ោង ១៣ និង ០០ នាទី រសៀល )។

**បញ្ហានៃនីតិវិធី ៖**

នៅថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៤ នាយកដ្ឋានវិវាទការងារ បានទទួលពាក្យបណ្តឹងតាមទូរស័ព្ទពីកម្មករនិយោជិត ស្តីពីការធ្វើកូដកម្មទាមទារសុំឱ្យក្រុមហ៊ុនផ្តល់ប្រាក់ឈ្នួល ១០០ ភាគរយ ក្នុងអំឡុងពេលកូដកម្មចាប់ពីថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៣ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ និងចាប់ពីថ្ងៃទី០២ ខែមករា ឆ្នាំ២០១៤ ដល់ថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៤។ បន្ទាប់ពីបានទទួលពាក្យបណ្តឹងនេះមក នាយកដ្ឋានវិវាទការងារ បានចាត់មន្ត្រីជំនាញឱ្យធ្វើការដោះស្រាយវិវាទការងារនេះ ដល់ទីតាំងក្រុមហ៊ុននៅថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៤ ដោយមិនទទួលបានលទ្ធផលសះជានឹងគ្នាទេ ទៅលើការទាមទារចំនួន ០១ ចំណុច។ ចំណុចមិនសះជាចំនួន ០១ ចំណុចនេះ ត្រូវបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅថ្ងៃទី១០ ខែមករា ឆ្នាំ២០១៤ តាមរយៈរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួម លេខ ០២១ ក.ប/អក/វក ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១៤។

កូដកម្មនៅតែបន្ត បន្ទាប់ពីសំណុំរឿងត្រូវបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាល។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានទទួលលិខិតរបស់ក្រុមហ៊ុន យៃនធើរេន អឺភែរីល (ខេមបូឌា) ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១៤ ស្តីពីសំណើសុំចេញសេចក្តីបញ្ជា ដើម្បីផ្អាកការធ្វើកូដកម្មរបស់កម្មករនិយោជិត ដែលចាប់ផ្តើមពីថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៣ មក។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចេញសេចក្តីបញ្ជាលេខ ០០២/១៤ កបអ. ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៤ ឱ្យកូដករផ្អាកជាបន្ទាន់នូវការធ្វើកូដកម្មនៅក្រុមហ៊ុន យៃនធើរេន អឺភែរីល (ខេមបូឌា) រហូតដល់នីតិវិធីនៃអាជ្ញាកណ្តាលត្រូវបានចប់សព្វគ្រប់តាមនីតិវិធីច្បាប់ ហើយកូដករទាំងអស់ត្រូវត្រឡប់ចូលធ្វើការវិញ ចាប់ពីរសៀលថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៤ តទៅ តាមវេនរបស់ខ្លួន។ ក៏ប៉ុន្តែ កូដករនៅតែបន្តធ្វើកូដកម្មដដែល ដោយកូដករមិនបានគោរពតាមសេចក្តីបញ្ជារបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនេះទេ។

ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានអញ្ជើញភាគីទាំងពីរមកសាកសួរព័ត៌មានបន្ថែម ក្នុងកិច្ចប្រជុំមុនសវនាការអាជ្ញាកណ្តាលនាថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៤ នៅវេលាម៉ោង ១៣៖០០ នាទី រសៀល។ ភាគីទាំងពីរមានវត្តមានតាមការអញ្ជើញ។

ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងធ្វើការពិចារណា និងសម្រេចដូចខាងក្រោម៖

**ភស្តុតាង**

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

**ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

**ក- ឯកសារបានទទួលពីភាគីនិយោជក ៖**

១- លិខិត ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១៤ របស់ក្រុមហ៊ុន ឃែនធើរេន អ៊ីភែរីល (ខេមបូឌា) គោរពជូនក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីសំណើសុំចេញសេចក្តីបញ្ជា ដើម្បីផ្អាកការធ្វើកូដកម្មរបស់កម្មករ-និយោជិត ។

២- លិខិតចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៤ របស់ក្រុមហ៊ុន ឃែនធើរេន អ៊ីភែរីល (ខេមបូឌា) គោរពជូនក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីរាយការណ៍ជូន ស្តីពីកម្មករនិយោជិតដែលកំពុងធ្វើកូដកម្ម មិនចូលធ្វើការតាមសេចក្តីបញ្ជារបស់ក្រុមប្រឹក្សាអជ្ញាកណ្តាល ។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖** គ្មាន

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ឃែនធើរេន អ៊ីភែរីល (ខេមបូឌា) លេខ ០២១ កប/អក/វក ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១៤។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមរបស់ក្រុមហ៊ុន ឃែនធើរេន អ៊ីភែរីល (ខេមបូឌា) ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៤។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមផ្តល់ពតិមានលំអិត លេខ ០៦១ កប/អក/វក/លកអ. ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៤។

២- លិខិតអញ្ជើញភាគីនិយោជកចូលរួមផ្តល់ពតិមានលំអិត លេខ ០៦២ កប/អក/វក/លកអ. ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៤។

៣- សេចក្តីបញ្ជារបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ០០២/១៤ កបអ. ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៤។

**អង្គហេតុ ៖**

មិនមានការរកឃើញអង្គហេតុ ទាក់ទងទៅនឹងចំណុចបញ្ហាវិវាទនៅក្នុងរបាយការណ៍មិនសះជា ដែលនាយកដ្ឋានវិវាទការងារបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ ដោយសារក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនបានដំណើរការ សវនាការ ។

**ហេតុផលនៃសេចក្តីសម្រេច ÷**

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើត្រូវបន្តនីតិវិធីអាជ្ញាកណ្តាលដែរ ឬទេ?

ប្រការ ២០ នៃប្រកាសលេខ ០៩៩ សកបយ របស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចែងថា ៖ *“ក្នុងអំឡុងពេលនៃដំណើរការរបស់ក្រុមអាជ្ញាកណ្តាល ភាគីវិវាទទាំងឡាយត្រូវផ្អាករាល់វិធានការវិវាទ ដូចជាកូដកម្ម ឬឡុកអៅ (ដូចមានចែងក្នុងមាត្រា ៣១៨ នៃច្បាប់ស្តីពីការងារ) ឬវិធានការដទៃទៀត ដែលអាចធ្វើឱ្យស្ថានភាពវិវាទកាន់តែធ្ងន់ធ្ងរ ។ ភាគីទាំងនេះត្រូវតែចូលរួមគ្រប់កិច្ចប្រជុំទាំងឡាយដែលក្រុមអាជ្ញាកណ្តាលបានអញ្ជើញឱ្យចូលរួម ”* ។

យោងតាមប្រការ ២០ នៃប្រកាសលេខ ០៩៩ ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីវិវាទត្រូវផ្អាករាល់វិធានការវិវាទ ដូចជាកូដកម្ម ឬឡុកអៅ ឬវិធានការដទៃទៀត ដែលអាចធ្វើឱ្យស្ថានភាពវិវាទកាន់តែធ្ងន់ធ្ងរ នៅក្នុងដំណើរការអាជ្ញាកណ្តាល ។

នៅក្នុងសេចក្តីបង្គាប់មុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបកស្រាយមាត្រានេះថា ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងមិនបន្តដំណើរការអាជ្ញាកណ្តាលទេ នៅពេលណាភាគីកម្មករនិយោជិត កំពុងធ្វើកូដកម្ម ឬនិយោជកធ្វើឡុកអៅ ។ (សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ *៥៩/០៦-សាង វ៉ូ ,លេខ៣៩/០៨-ចុង យ៉ូវ, លេខ ១៣៧/០៩, ១៣៨/០៩-ញ៉ូ ភាញ់, លេខ ១១០/១១-ស៊ីម៉ាណូ និងលេខ ១០៤/១៣- ប្រ៊ីណា (ខេមបូឌា)*) ។

ឧទាហរណ៍ នៅក្នុងសំណុំរឿងលេខ ០៤/០៤-អិម អេស អាយ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចេញសេចក្តីជូនដំណឹងមួយ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៤ ដែលកថាខ័ណ្ឌទី៤ នៃសេចក្តីជូនដំណឹងនេះ កំណត់ថា ៖

*“ដោយពិនិត្យឃើញថា ភាគីនៃវិវាទការងារនេះមិនមានសិទ្ធិធ្វើកូដកម្ម ក្នុងកំឡុងពេលនៃដំណើរការរបស់អាជ្ញាកណ្តាល ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនអាចធ្វើការដោះស្រាយ ឬក៏ចេញសេចក្តីបង្គាប់លើវិវាទការងាររួមនេះ បានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាលឡើយ ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលអាចដោះស្រាយវិវាទការងាររួមនេះម្តងទៀតបាន នៅពេលណាដែលសហជីពកម្មករនិយោជិតទាំងអស់ឈប់ធ្វើកូដកម្ម ”*។

ដូចគ្នាដែរ នៅក្នុងសំណុំរឿងលេខ ១៨/០៤-សណ្ឋាគារ (កាំបូឌីយ៉ាណា, រ៉ាហ្វែល ឡឺរ៉ូយ៉ាល់, រ៉ាហ្វល ប្រេ្កនឌិ អង្គរ,សាន់វេ, អ៊ិនធើខនធីណេនថល និង សូហ្វីតែល អង្គរ) ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចេញសេចក្តីបញ្ជាទីពីរ ចុះថ្ងៃទី ២២ ខែមេសា ឆ្នាំ២០០៤ ត្រង់ចំណុចទី៩ និងទី១១ នៃសេចក្តីបញ្ជានេះចែងដូចខាងក្រោម ៖

*“ចំណុចទី៩- ចាប់ពីថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០៤ តទៅ កម្មករនិយោជិតទាំងអស់ត្រូវបញ្ឈប់កូដកម្ម បាតុកម្ម ឬ ការរំខានណាមួយ នៅក្នុងបរិវេណសណ្ឋាគារនានា ដែលជាភាគីនៃវិវាទនេះ ”* ។

*“ចំណុចទី ១១-ក្រុមប្រឹក្សាអាជ្ញាកណ្តាលរក្សាសិទ្ធិក្នុងការបញ្ចប់ដំណើរការអាជ្ញាកណ្តាល ករណីដែលភាគីណាមួយបំពានប្រការណាមួយនៃសេចក្តីបញ្ជានេះ ”* ។

នៅក្នុងសំណុំរឿងលេខ ៧៧/០៥-ប្រហ្វង់កូ នីតធីង ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចេញសេចក្តីបញ្ជាទី២ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០០៥ ហើយបានចែងនៅក្នុងចំណុចទី៤ថា នៅក្នុងករណីដែលភាគីកម្មករនិយោជិតបន្តធ្វើកូដកម្ម ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងមិនដំណើរការដោះស្រាយវិវាទការងាររួមនេះទេ ។

THE ARBITRATION COUNCIL

នៅក្នុងសំណុំរឿងលេខ ១១០/១១-ស៊ីម៉ាណូ និងសំណុំរឿងលេខ ១៧/១៣-អ៊ិនធើណាស្យូណាល់ ហ្វេស៊ិន វ៉ូយ៉ាល់ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលក៏បានចេញសេចក្ដីបង្គាប់មិនបន្តដំណើរការអាជ្ញាកណ្ដាល ដោយមូលហេតុ កម្មករនិយោជិតនៅតែបន្តធ្វើកូដកម្មក្នុងអំឡុងពេលដំណើរការនីតិវិធីរបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាលដែរ។

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលក៏យល់ស្របតាមការសម្រេច របស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាលក្នុងសំណុំរឿងខាងលើដែរ។

ក្រុមប្រឹក្សាអាជ្ញាកណ្ដាលបានកោះហៅភាគីទាំងពីរមកបំភ្លឺលើករណីកូដកម្មនេះ នៅថ្ងៃទី១៦ ខែមករា ឆ្នាំ ២០១៤ វេលាម៉ោង ១៣៖០០ នាទី រសៀល។ ភាគីទាំងពីរមានវត្តមាន តាមការកោះអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាល និងបានអះអាងថា កូដកម្មនៅតែបន្ត។ សរុបមក ភាគីកម្មករនិយោជិត នៅតែបន្តធ្វើកូដកម្ម និងមិនគោរពតាមសេចក្ដីបញ្ជារបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាល ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៤ ឡើយ។

ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលសម្រេចបញ្ចប់ដំណើរការអាជ្ញាកណ្ដាលក្នុងសំណុំរឿងនេះ។

យោងតាមអង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលសម្រេចចេញសេចក្ដីបង្គាប់ដូចតទៅ៖

## សម្រេច និង បង្គាប់

- បញ្ចប់ដំណើរការអាជ្ញាកណ្ដាលក្នុងសំណុំរឿងលេខ ០០៥/១៤-ឃែនធើរេន អ៊ីកែវីល (ខេមបូឌា)។

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្ដាល**

**អាជ្ញាកណ្ដាលជ្រើសរើសដោយភាគីនិយោជក៖**

ឈ្មោះ៖ **ម៉ារ សំបូរណា**

ហត្ថលេខា៖ ---------------------------

**អាជ្ញាកណ្ដាលជ្រើសរើសដោយភាគីកម្មករនិយោជិត៖**

ឈ្មោះ៖ **អន ណាន**

ហត្ថលេខា៖ ---------------------------

**ប្រធានក្រុមអាជ្ញាកណ្ដាល៖**

ឈ្មោះ៖ **គង់ ផល្លះ**

ហត្ថលេខា៖ ---------------------------